# II- រាជរដ្ឋាភិបាល

## ១- អនុក្រឹត្យ

### អនុក្រឹត្យលេខ ០៦ អនក្រ.បក
### ស្តីពី
### ការរៀបចំថ្នាក់សិស្សពូកែផ្នែក គណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និង រូបវិទ្យា

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំថ្នាក់សិស្សពូកែ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

**មាត្រា ១ .-** អនុញ្ញាតឲ្យក្រសួង អប់រំ យុវជន និងកីឡា បង្កើតថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យាតាមកំរិតថ្នាក់នីមួយៗ នៅមធ្យមសិក្សាដើម្បីពង្រឹងគុណភាពអប់រំនៃមុខ វិជ្ជាមូលដ្ឋាន និងដាស់ចលនាប្រឡងប្រណាំងរៀនសូត្ររបស់សិស្សានុសិស្សអោយកាន់តែល្អប្រសើរ សំដៅអភិវឌ្ឍធនធានមនុស្ស ប្រកបដោយសីលធម៌និងចំណេះដឹងខ្ពង់ខ្ពស់ ។

មាត្រា ២._ -វិទ្យាល័យ ឬអនុវិទ្យាល័យ អាចរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា តាមគំនិតច្នៃប្រឌិតរបស់ខ្លួន ។

មាត្រា ៣._ -ការសម្រេចអោយឡើងថ្នាក់សិស្សពូកែខ្ពស់ជាងបន្ទូបន្ទាប់ ឬ ការបញ្ជូនអោយទៅរៀនថ្នាក់ធម្មតាវិញ ជាសមត្ថកិច្ចផ្ទាល់របស់គ្រឹះស្ថានមធ្យមសិក្សា ឈរលើបេក្ខភាពវិនិច្ឆ័យមួយ ដែលជាគំនិតផ្តួចផ្តើមរបស់គណៈគ្រប់គ្រងសាលារៀន ។

មាត្រា ៤._ -គ្រប់ខេត្ត-ក្រុង និងគ្រប់គ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទផ្ទាល់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវចាត់ចែងធ្វើការប្រឡងជ្រើសរើសសិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា សំរាប់ថ្នាក់បញ្ចប់មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ។

មាត្រា ៥._ -ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំធ្វើការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យាសំរាប់ថ្នាក់បញ្ចប់មធ្យមសិក្សា បឋមភូមិ និងថ្នាក់បញ្ចប់មធ្យមសិក្សាទុតិយភូមិ ក្នុងចំណោមបេក្ខជនសិស្សពូកែដែល ខេត្ត-ក្រុងបានធ្វើការប្រឡងជ្រើសរើសរួចហើយ ។

មាត្រា ៦._ -ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស នឹងប្រព្រឹត្តទៅនៅខេត្ត-ក្រុងណាមួយ ទាំងវិញ្ញាសារសរសេរ និងកំណែ ។ ប្រធានវិញ្ញាសាចេញដោយក្រសួងអប់រំ យុវជន និងកីឡា ដោយគិតតាមកម្មវិធីសិក្សាពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ សំរាប់សិស្សថ្នាក់ទី៩ និងពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ សំរាប់សិស្សថ្នាក់ទី១២ ។

មាត្រា ៧._ -បេក្ខជនសិស្សពូកែទូទាំងប្រទេស អាចជ្រើសរើសយកបានតែមួយមុខវិជ្ជាប៉ុណ្ណោះ ។ បេក្ខជនម្នាក់ៗ ត្រូវធ្វើការប្រឡងជាបីពេល លើមុខវិជ្ជាដែលសាមីខ្លួនបានជ្រើសរើសពីរពេល និងលើមុខវិជ្ជាវប្បធម៌ទូទៅមួយពេល ។

មាត្រា ៨._ -នឹងត្រូវប្រកាសថា ជាជ័យលាភី ក្នុងការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស បេក្ខជន ដែលបានពិន្ទុចាប់ពីមធ្យមឡើងទៅ លើមុខវិជ្ជាវប្បធម៌ទូទៅ លើមុខវិជ្ជាឯកទេស និងបានពិន្ទុលើសគេចំនួន ១០នាក់ ដំបូងតាមមុខវិជ្ជាឯកទេស និងតាមកំរិតថ្នាក់ ។ ជ័យលាភីម្នាក់ៗ ត្រូវបានទទួលរង្វាន់ពីរដ្ឋទៅតាមចំណាត់ថ្នាក់ និងសំភារៈផ្សេងៗ ដូចខាងក្រោម :

១- ប្រកាសទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡាមួយច្បាប់

២- មេដាយមួយគ្រឿង (ពីលេខ ១ ដល់លេខ ៣)

៣- វិញ្ញាបនប័ត្រសិស្សពូកែទូទាំងប្រទេសមួយសន្លឹក

៤- ប្រាក់រង្វាន់

| | | | |
|---|---|---|---|
| លេខ ១ | ៨០០.០០០ ៛ | លេខ ៦ | ៦៥០.០០០ ៛ |
| លេខ ២ | ៧៧០.០០០ ៛ | លេខ ៧ | ៦២០.០០០ ៛ |
| លេខ ៣ | ៧៤០.០០០ ៛ | លេខ ៨ | ៥៩០.០០០ ៛ |
| លេខ ៤ | ៧១០.០០០ ៛ | លេខ ៩ | ៥៦០.០០០ ៛ |
| លេខ ៥ | ៦៨០.០០០ ៛ | លេខ ១០ | ៥៣០.០០០ ៛ |

៥- ប្រាក់រង្វាន់ ឬវត្ថុផ្សេងៗពីសប្បុរសជន

**មាត្រា ៩.-** -ក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចរៀបចំពិធីបើកការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស និងរៀបចំពិធីចែករង្វាន់ជលជ័យលាភីសិស្សពូកែទូទាំងប្រទេសផ្នែកគណិតវិទ្យា អក្សរសិល្បខ្មែរ និងរូបវិទ្យា អោយបានសមរម្យ ។

**មាត្រា ១០.-** -គណៈមេប្រយោគប្រឡងសិស្សពូកែទូទាំងប្រទេស ត្រូវធ្វើការ និងទទួលប្រាក់ឧបត្ថម្ភតាមរបបម៉ោងបន្ថែមដោយគិតក្នុងមួយថ្ងៃធ្វើការ ៦ម៉ោងបន្ថែម ហើយប្រាក់កំរៃមួយម៉ោង ស្មើនឹងប្រាក់កំរៃនៃមួយម៉ោងបន្ថែមរបស់សាស្ត្រាចារ្យមធ្យមសិក្សាទុតិយភូមិ ។ ការចាត់តាំងគណៈមេប្រយោគប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ជាសមត្ថកិច្ចរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ១១ .-** -សំភារៈចាំបាច់ផ្សេងៗ ថវិកាប្រឡង សោហ៊ុយរៀបចំពិធីបើកការប្រឡង និងពិធីចែករង្វាន់ សោហ៊ុយធ្វើដំណើរ ស្នាក់នៅហូបចុក សំរាប់ដំណើរការប្រឡងសិស្សពូកែទូទាំងប្រទេស និងដំណើរកំសាន្តរបស់បេក្ខជន ជាបន្ទុករបស់រាជរដ្ឋាភិបាល ។ បញ្ជីចំណាយផ្សេងៗ នឹងមានចែងក្នុងអត្ថបទមួយ ។

**មាត្រា ១២.-** -អនុក្រឹត្យលេខ ២៨ អនក្រ.ប្រក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែក គណិតវិទ្យា និងអក្សរសិល្បខ្មែរ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៣.-** -រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

***